**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបិទកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៣
## នៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣

ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលកំពុងមានវត្តមានដ៏ឧត្តុង្គឧត្តមក្នុងកិច្ចប្រជុំនាពេលនេះ!

ឆ្លងកាត់នូវការចំណាយពេលដ៏មានតម្លៃពេញមួយព្រឹក កិច្ចប្រជុំពេញអង្គរបស់យើងបានធ្វើបទបង្ហាញ ពិភាក្សា និងផ្តល់យោបល់យ៉ាងសកម្ម ដែលនាំឱ្យយើងទទួលបាននូវលទ្ធផលគួរជាទីមោទនៈ ស្របទៅនឹងកម្មវត្ថុនៃកិច្ចប្រជុំនាពេលនេះ ដែលខ្ញុំសូមសង្ខេបជូនដូចតទៅ ៖

**ទី១ :** ការអនុម័តនូវរបាយការណ៍វឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផលក្នុងការឆ្លើយតបនឹងការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ រយៈពេល៦ខែចុងឆ្នាំ២០២៣។

**ទី២ :** ការបន្តជំរុញឱ្យមានវឌ្ឍនភាព និងបន្តអនុវត្ត លិខិតលេខ ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីវិធានការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

**ទី៣ :** ការរៀបចំគោលនយោបាយជាតិលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពនៃកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ទោះបីជាយើងមានពេលតែមួយព្រឹកក៏ពិតមែន ប៉ុន្តែដោយសារមានការចូលរួមយ៉ាងសកម្មពីឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាបានធ្វើឱ្យយើងអាចទទួលបាននូវលទ្ធផលជាវិជ្ជមាន។ ខ្ញុំសូមថ្លែងនូវការកោតសរសើរដ៏ស្មោះចំពោះសមាជិក សមាជិកានៃអង្គពិធីទាំងមូល។

ក្នុងឆ្នាំ២០២៣នេះ រាជរដ្ឋាភិបាលបានវិភាជន៍រួចហើយនូវថវិកាចំនួន៦០លានរៀលក្នុងមួយឆ្នាំ ដល់ខេត្តចំនួន១១បន្ថែមទៀត បន្តពីការផ្តល់ថវិកាចំនួន៨០លានរៀល ដល់រាជធានីភ្នំពេញ និងខេត្តសរុបចំនួន៤ កាលពីឆ្នាំ២០២២។ ទន្ទឹមនឹងនេះ នៅឆ្នាំ២០២៤ខាងមុខ រាជរដ្ឋាភិបាលក៏បានគ្រោងវិភាជថវិកាចំនួន៤០លានរៀលក្នុងមួយឆ្នាំក្នុងមួយខេត្ត ដល់ខេត្តចំនួន១០ ចុងក្រោយទៀតផងដែរ។ សរុបមក ចាប់ពីឆ្នាំ២០២២ ដើម្បីជំរុញការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបាននិងគ្រោងវិភាជន៍ថវិកាចំនួន១.៣៨០លានរៀលក្នុងមួយឆ្នាំ ដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តទាំង២៥ សម្រាប់កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ។

ខ្ញុំសូមអនុញ្ញាតឆ្លៀតឱកាសមុនបិទកិច្ចប្រជុំពេញអង្គរបស់យើង ផ្តល់ជូននូវចំណាប់អារម្មណ៍បូកសរុបលទ្ធផលជារួមដែលទទួលបានពីកិច្ចប្រជុំនេះដូចខាងក្រោម ៖

១) ជារួម យើងទាំងអស់គ្នាពិតជាបានខិតខំអនុវត្តផែនការសកម្មភាព រយៈពេល៦ខែចុងឆ្នាំ ២០២៣ នៅតាមក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

២) សូមអបអរសាទរចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលបានចូលរួម និងផ្តួចផ្តើមឱ្យមានកិច្ចប្រជុំនានា ដើម្បីឆ្លើយតបនឹង "លិខិតលេខ ២១៣សជណ.សស ដែលមកទល់ពេលនេះ បានសម្របសម្រួលដល់ការផ្តល់ និងប្រើប្រាស់កញ្ចប់ថវិកាជាតិ ក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់បណ្តាខេត្តដែលមានហានិភ័យផ្សេងទៀត។

៣) អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំ និងដាក់ឱ្យដំណើរការគោលនយោបាយជាតិលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពនៃកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។

៤) អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បន្តសហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំបញ្ចប់ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យ លើកទី៦ ឆ្នាំ២០២៤-២០២៨។

៥) អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បន្តសហការជាមួយ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីសិក្សាលើលទ្ធភាពប្រើប្រាស់ អត្ថប្រយោជន៍គាំពារសង្គមក្នុងការគាំទ្រដល់ការងារឆ្លើយតបនឹងការរាលដាលមេរោគអេដស៍។ ជាពិសេសការលើកទឹកចិត្តឱ្យប្រជាជនគន្លឹះស្ម័គ្រចិត្តមកធ្វើតេស្តឈាមរកមេរោគអេដស៍អាចចាត់ទុកជាមធ្យោបាយមួយក្នុងការបង្កើនការមកទទួលយកសេវាសុខភាព រួមទាំងការធ្វើតេស្តឈាមរកមេរោគអេដស៍ផងដែរ។

ជាមួយគ្នានេះផងដែរ ខ្ញុំសូមផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

១) អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវប្រមូលរាល់ធាតុចូល និងអនុសាសន៍ទាំងអស់ដែលបានអនុម័តជាគោលការណ៍នៅក្នុងកិច្ចប្រជុំនេះ ដើម្បីយកទៅរៀបចំ និងកែសម្រួលសម្រាប់ដាក់ចេញនូវគម្រោងផែនការសកម្មភាពនាពេលខាងមុខ។

២) បន្តជំរុញ និងប្រើប្រាស់គ្រប់យន្តការទាំងអស់ ដើម្បីធ្វើឱ្យសម្រេចបានជោគជ័យក្នុងការអនុវត្តលិខិតលេខ ២១៣សជណ.សស។

៣) បន្តជំរុញ និងលើកទឹកចិត្តក្រសួង ស្ថាប័ន ដែលពុំទាន់បានទទួលថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យលើកសំណើថវិកា ក្នុងកញ្ចប់នៃផែនការថវិការបស់ក្រសួង ស្ថាប័នសាមីឱ្យបានព្រមៗគ្នា។

៤) បន្តជំរុញការអនុវត្ត រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីសម្រេចឱ្យបានជោគជ័យនូវ កម្មវិធីគំនិតផ្តួចផ្តើមទីក្រុងរួមគ្នាពន្លឿនការឆ្លើយតបការរីករាលដាលជំងឺអេដស៍ (Fast-Track Cities Initiative) ដែលបាននិងកំពុងដំណើរការ នៅក្នុងរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ។

៥) សូមលើកទឹកចិត្ត ក្រសួងផែនការ ក្រសួងសុខាភិបាល និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បន្តធ្វើការសហការ ជំរុញ និងកែសម្រួលនូវកម្មវិធីគ្រួសារក្រីក្រ ដោយផ្តល់ប័ណ្ណក្រីក្រ ដល់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ជាបុគ្គលនៅតាម កន្លែងផ្តល់ឱសថប្រឆាំងនឹងមេរោគអេដស៍ និងដាក់បញ្ចូលទៅក្នុងប្រព័ន្ធកម្មវិធីគ្រួសារក្រីក្រ ថ្នាក់ជាតិរបស់ក្រសួងផែនការ។

៦) បង្កើនតំបន់គ្របដណ្តប់កម្មវិធី ប្រិប (PrEP) ឱ្យបានទូលំទូលាយ និងកាន់តែមានប្រសិទ្ធភាព។ បន្តរុករកអ្នកដែលមិនទាន់បានមកទទួលសេវា ឱ្យមកទទួលយកសេវា បង្កើនការគ្របដណ្តប់ និងផ្តល់អន្តរាគមន៍ឱ្យមានប្រសិទ្ធភាព ទៅលើក្រុមប្រឈម ពិសេសក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ។

៧) បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីទទួលបានជំនួយទាំងសម្ភារ ថវិកា និងបច្ចេកទេស សម្រាប់ចីរភាពកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជាសម្រេចបានជោគជ័យក្នុងការលុបបំបាត់ជំងឺអេដស៍ជាស្ថាពរ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំពេញអង្គដ៏មានសារៈសំខាន់នាពេលនេះ។ តាមរយៈការចូលរួមយ៉ាងសកម្ម ការផ្តល់នូវគំនិតយោបល់ល្អៗ និងមានតម្លៃ នាំឱ្យយើងអាចយកទៅប្រើប្រាស់ក្នុងការកែលម្អការអនុវត្តការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត។

ខ្ញុំសូមថ្លែងការកោតសរសើរផងដែរចំពោះ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានខិតខំរៀបចំកិច្ចប្រជុំពេញអង្គនេះ ឱ្យប្រព្រឹត្តទៅបានដោយរលូន និងសម្រេចបាននូវលទ្ធផលគួរជាទីមោទនៈ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់នូវជ័យមង្គលមហាប្រសើរ សេចក្តីសុខសេចក្តីចម្រើន ប្រាជ្ញាឈ្លាសវៃ ដើម្បីបន្តការកិច្ចរួមជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទទួលបានជោគជ័យថ្មីៗបន្ថែមទៀត។

ខ្ញុំសូមប្រកាសបិទ “**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ ២០២៣**” ចាប់ពីពេលនេះតទៅ។

សូមអរគុណ!